ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ និងទិសដៅការងារខែមីនា ឆ្នាំ២០២៣

នៅក្នុងខែកុម្ភៈនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្ដល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

-បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

២-សេចក្ដីព្រាងច្បាប់ស្ដីពី ការគ្រប់គ្រងទឹកស្អាត

-បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីពិនិត្យសិក្សាលើសេចក្ដីព្រាងច្បាប់ចំនួន០២ច្បាប់

-បានរៀបចំប្រជុំគណៈកម្មការកែសម្រួលបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

**២- មុខងារតាមដានការអនុវត្តច្បាប់**

-បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា៖

+អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិត ហេង សុផាឌី សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសហការី ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ស្ថិតនៅសាលប្រជុំសាកលវិទ្យាល័យវិចិត្រសិល្បៈ

+អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់ខេត្ត បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ពាក់ព័ន្ធនឹងវិស័យកសិកម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ បរិស្ថាន វិនិយោគ និងលទ្ធផលការងាររបស់មន្ទីរពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ព្រមទាំងការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល

+អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធកិច្ចប្រតិបត្តិការរបស់អភិបាល នៃគណៈអភិបាលខេត្ត មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត ស្នងការនគរបាលខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងមន្ទីរមុខងារសាធារណៈ និងបញ្ហាប្រឈមនានា

+អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំអភិវឌ្ឍន៍លើគ្រប់វិស័យក្នុងខេត្តព្រះសីហនុ ក្នុងគោលដៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ជាអាទិ៍ ដំណើរការអភិវឌ្ឍកំពង់ផែអន្តរជាតិក្រុងព្រះសីហនុទៅជាកំពង់ផែទឹកជ្រៅកម្រិត១ ក្នុងជម្រៅ១៤.៥ម៉ែត្រ សម្រាប់ឆ្នាំ២០២៦ តាមរយៈហិរញ្ញប្បទានពីព្រះរាជាណាចក្រជប៉ុន, ដំណើរការអភិវឌ្ឍព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុឱ្យក្លាយទៅជាព្រលានយន្តហោះប្រភេទ4E, ការងារដោះស្រាយគម្រោងសំណង់អគារជាប់គាំងក្នុងខេត្តព្រះសីហនុ និងជំរុញការការពារ និងថែរក្សាប្រភពទឹកទៅ ក្នុងគោលដៅពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាតសម្រាប់ខេត្តព្រះសីហនុឱ្យបានដល់តំបន់ដាច់ស្រយាល ដោយអនុលោមទៅតាមប្រសាសន៍ដ៏ថ្លៃថ្លារបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** គឺ "ទឹកស្អាតសម្រាប់ទាំងអស់គ្នា"

+អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ លទ្ធផលនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ វឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអភិវឌ្ឍមូលដ្ឋាន

+អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន និងការបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព នៅខេត្តតាកែវ។

**៣-មុខងារតំណាង**

-បានរៀបចំចាត់ចែង ផ្តល់សេវា និងអមដំណើរៈ

+**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

▪ថ្វាយព្រះរាជដំណើរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងពិនិត្យ និងព្យាបាលព្រះរាជ

សុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

▪អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពលោកជំទាវ **ប៊ុន សុថា** ភរិយាឯកឧត្ដម តាន់ បញ្ញារុធ និងត្រូវជាប្អូនបង្កើតសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅរាជធានីភ្នំពេញ

+**ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តមុខងារតំណាងរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភាឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

+**ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ង៉ន** អនុប្រធានទី២ព្រឹទ្ធសភា

▪អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ដើម្បីពិនិត្យពិភាក្សាលើរបាយការណ៍ចំណូល-ចំណាយប្រចាំឆ្នាំ២០២២ ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅការងារសម្រាប់អនុវត្តបន្តប្រចាំឆ្នាំ២០២៣

▪អញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តមុខងារតំណាងឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា

▪អញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ចុះជួបសំណេះសំណាល និងប្រគល់ឧបករណ៍តេស្តកូវីដ-១៩ ព្រមទាំងថវិកាជូនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង ប្រធានមណ្ឌលសុខភាព និងប្រធានមន្ទីរពេទ្យបង្អែកចំនួន៣៧៥នាក់ តាមបណ្ដាស្រុក ក្រុងទាំង១១ ទូទាំងខេត្តកណ្ដាល

▪អញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកាថ្នាក់ខណ្ឌជាមួយក្រុមប្រឹក្សាសង្កាត់ទាំង៥ខណ្ឌ ស្ដីពី ការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវាជូនប្រជាជនប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ

▪អញ្ជើញនាំយកទេយ្យទាន ចង្ហាន់ និងបច្ច័យប្រគេនព្រះសង្ឃគង់នៅវត្តប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

+លោកជំទាវ **ជា ច័ន្ទទេវី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញដង្ហែបុណ្យផ្កាប្រាក់ស្មើសាមគ្គីទៅកាន់វត្តឧត្ដមមានជ័យសិរីមហាតេជោ និងអញ្ជើញពិនិត្យការសាងសង់ព្រះវិហារនៅវត្តព្រះសារីបុត្រសែនជ័យ ស្រុកស្នួល ខេត្តក្រចេះ

+លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ព្រះវិហារថ្មី នៅវត្តកំពង់ស្វាយ និងអញ្ជើញជាគណៈអធិបតីក្នុងពិធី

សំណេះសំណាល អបអរសាទរខួបលើកទី១១២ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៣ ក្រោមប្រធានបទ "ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" នៅខេត្តកំពង់ធំ

+សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ អញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាសង្កាត់ចំនួន១០ខណ្ឌ ស្តីពី ការអភិវឌ្ឍមូលដ្ឋានសង្កាត់ ខណ្ឌ ការងារភូមិ សង្កាត់មានប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ នៅរាជធានីភ្នំពេញ

+សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធឧបាសិកា **ស៊ីន ឡាំងអេង** ម្តាយលោកស្រី **ឆាយ ចិន្តា** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

+សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយ និងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋ អញ្ជើញទៅចាក់វ៉ាក់សាំងដូសជំរុញការពារជំងឺកូវីដ-១៩ ឱ្យបានគ្រប់ៗគ្នា ជាពិសេសបាននាំយកថ្នាំពេទ្យ បរិក្ខារពេទ្យ ឧបករណ៍តេស្តរហ័សជូនអាជ្ញាធរ និងមណ្ឌលសុខភាព នៅតាមបណ្តាខេត្ត ក្រុងនានាចំនួន១០៣លើក ព្រមទាំងបានចូលរួមពិធីផ្សេងៗចំនួន៧៨លើក

-បានរៀបចំជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ង៉ន** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះទៅពិនិត្យ និងព្យាបាលជំងឺ ជូនប្រជាពលរដ្ឋក្រីក្រ នៅខេត្តកណ្តាល

-ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការ និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខដាច់ដោយឡែកពីគ្នាជាមួយអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក សង្កាត់ព្រែកលៀប សង្កាត់បាក់ខែង និងសង្កាត់កោះដាច់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋក្រីក្រ នៅសង្កាត់កោះដាច់ សង្កាត់ព្រែកលៀប និងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និស្សិត និងសិស្សនៃសាលារៀនខេម-អាស៊ានចំនួន៩០នាក់

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៣៦នាក់

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ចំនួន៨០០ក្បាល

-បានរៀបចំផលិតខ្សែវីដេអូសមិទ្ធផលស្តីពី លទ្ធផលការងារក្នុងរយៈពេល១ឆ្នាំក្នុងមុខងារតំណាងរបស់ព្រឹទ្ធសភា ប្រចាំឆ្នាំ២០២២

-បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន៨០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និងរៀបចំអំណោយចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលសម្តេចនាយករដ្ឋមន្ត្រី ទទួលបានមេដាយថ្នាក់ខ្ពស់បំផុត "មេដាយផ្ទៃសៃឡានសាង" ពីឯកឧត្តមបណ្ឌិត **ថងលួង ស៊ីសូលីត** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងសមាជិកព្រឹទ្ធសភា គោរពជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ក្នុងឱកាសចម្រើនអាយុវឌ្ឍនមង្គលរបស់សម្តេចគម្រប់៧៨ ឈានចូល៧៩ឆ្នាំ

-បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានាចំនួន០៦លិខិត

-បានរៀបចំ និងផ្ញើសាររំលែកទុក្ខក្នុងនាមថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦លិខិត និងចូលរួមពិធីគោរពវិញ្ញាណក្ខន្ធរបស់ឥស្សរជនជាន់ខ្ពស់តាមក្រសួងស្ថាប័ននានាចំនួន០៤លើក

-បានទទួលពាក្យបណ្តឹងចំនួន០៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៧ករណី កំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៦ករណី តម្កល់ទុកមិនចាត់ការចំនួន០៦ករណី។

**៤-មុខងារសហប្រតិបត្តិការអន្តរជាតិ**

-បានរៀបចំចាត់ចែង និងផ្តល់សេវាជូន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រមុខរដ្ឋស្តីទី៖

+ទទួលបដិសណ្ឋារកិច្ច ជួបសវនាការ និងរៀបចំពិធីលៀងសាយភោជន៍ជូនឯកឧត្តម

បណ្ឌិត **ហ្វាំងវ៉ាល់ឆ័រ ផ្ទែនម៉ៃយ័រ** ប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងឱកាសនៃដំណើរបំពេញទស្សនកិច្ចជាផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា

+ក្នុងពិធីជូនសារតាំង ជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្ដម **អ៊ូអ៊ិណូ អាតស៊ូហ៊ីរ៉ូ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រជប៉ុន ទើបតែងតាំងថ្មី, ឯកឧត្ដម **ផាក ជុងវុក** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភានៃសាធារណរដ្ឋកូរ៉េ, ឯកឧត្ដម **ឈើតគាត អាត់ថាកន** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃឡង់ដ៍ ប្រចាំព្រះរាជាណាចក្រកម្ពុជា និងឯកឧត្ដម Victor Oh សមាជិកព្រឹទ្ធសភាកាណាដា

–បានរៀបចំចាត់ចែង និងផ្ដល់សេវាជូន**ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

–បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយសមាជិកព្រឹទ្ធសភាបារាំង និងលោក Greg Moran ភ្នាក់ងារស៊ុយអែត ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍអន្តរជាតិ Sida ក្នុងគោលបំណងដើម្បីឈ្វេងយល់ពីលទ្ធផលនៃការផ្ដល់សេវាគាំទ្រផ្នែកស្រាវជ្រាវ និងសារពើពន្ធ

–បានរៀបចំ សម្របសម្រួលបែបបទ ផ្ដល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិនានារួមមាន៖ អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំងនៅព្រះរាជាណាចក្រម៉ារ៉ុក, កិច្ចប្រជុំត្រៀមចូលរួមមហាសន្និបាតលើកទី១៤៥ របស់សហភាពអន្តរសភា(IPU) នៅព្រះរាជាណាចក្របារ៉ែន នៅវិមានព្រឹទ្ធសភា, កិច្ចប្រជុំក្រុមប្រឹក្សាភិបាល(PCA), ចូលរួមវេទិកាកម្រិតខ្ពស់ថ្នាក់តំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី១១ ស្ដីពី 3R និងសេដ្ឋកិច្ចវិលជុំ ក្រោមប្រធានបទ "Integrating Circular Economy in Major Development Sectors toward Achieving Zero Waste Societies andthe SDGs" ដើម្បីពង្រឹង និងពង្រីកបន្ថែមការអនុវត្តគោលការណ៍3R និងសេដ្ឋកិច្ចវិលជុំនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក សំដៅចូលរួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពី ការប្រែប្រួលអាកាសធាតុ, អញ្ជើញពិភាក្សាការងារជាមួយលោកជំទាវ **អ៊ូ ឃូខូចាអេសហ្វេ** ឯកអគ្គរដ្ឋទូតតួកគី ប្រចាំព្រះរាជាណាចក្រកម្ពុជា

–បានរៀបចំជូនសមាជិកព្រឹទ្ធសភា អញ្ជើញជាកិត្តិយសអបអរសាទរទិវាបុណ្យជាតិនៃប្រទេសគុយវ៉ែត និងអញ្ជើញជាកិត្តិយសអបអរសាទរពិធីចម្រើនព្រះជន្មព្រះចៅអធិរាជជប៉ុន នៅរាជធានីភ្នំពេញ

–ឯកឧត្ដម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បាន៖

+អនុញ្ញាតឱ្យគណៈប្រតិភូមូលនិធិចិន ដើម្បីសន្តិភាព និងការអភិវឌ្ឍ (CFPD) ចូលជួបសម្តែងការគួរសម

+អនុញ្ញាតឱ្យលោកស្រី **Sirpen Panprom** នាយកទីផ្សារនៃមន្ទីរពេទ្យPhya Thai និងជាតំណាងមន្ទីរពេទ្យនៅទីក្រុងបាងកកនៃព្រះរាជាណាចក្រថៃឡង់ដ៍ ចូលជួបពិភាក្សាការងារ ដើម្បីស្វែងរកនូវការប្រឹក្សាយោបល់ក្នុងការជួយជំរុញលើកកម្ពស់ការគាំទ្រដល់វិស័យឧស្សាហកម្មគាំពារសុខភាពប្រជាពលរដ្ឋ

–បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតសិង្ហបុរី, ស្ថានទូតចិន, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ស្ថានទូតវៀតណាម, អង្គការតម្លាភាពកម្ពុជា (TI Cambodia), មូលនិធិសន្តិភាពដើម្បីអភិវឌ្ឍ, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ(USTH), សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃទីក្រុងហាណូយ(RMIT), សាកលវិទ្យាល័យលីមកុកវីង, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, មជ្ឈមណ្ឌលសភាអាស៊ី(PCAsia), វិទ្យាស្ថានវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍, វិទ្យាស្ថាន Proseth, វិទ្យាស្ថានSunrise, វិទ្យាស្ថានSalaCyber, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិសង្គមកិច្ច, ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រថៃឡង់ដ៍(TICA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុន KOHA និងក្រសួង ស្ថាប័ន បណ្ណាល័យនានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន**

–បានរៀបចំជួសជុល តុបតែងកែលម្អសោភ័ណភាព ការងារអនាម័យ សន្តិសុខ ពិធីការ ការងារឯកសារសម្រាប់បម្រើឱ្យពិធីទទួលបដិសណ្ឋារកិច្ចប្រធានាធិបតី នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

–បានចូលរួមប្រជុំកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

–បានប្រជុំផ្សព្វផ្សាយការងារថ្មីៗពាក់ព័ន្ធនឹងការផ្តល់សេវារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានប្រជុំពិនិត្យសិក្សារបាយការណ៍ស្តីពី "ការស្ទង់មតិអំពីភាពពេញចិត្តចំពោះការងារ" របស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានប្រជុំគណៈកម្មការពិនិត្យការវាយតម្លៃដំឡើងថ្នាក់បៀវត្សជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានប្រជុំគណៈកម្មការត្រួតពិនិត្យបេឡាសោធននិវត្តន៍នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

–បានប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលសេចក្តីព្រាងសេចក្តីសម្រេចស្តីពី គោលការណ៍ផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាដែលមានស្នាដៃឆ្នើម

–បានប្រជុំត្រួតពិនិត្យ និងពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

-បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

**៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**

-បានរៀបចំបើកឯកសារដេញថ្លៃប្រេងឥន្ធនៈ ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងក្រុមហ៊ុនដែលបានដាក់ឯកសារដេញថ្លៃ

-បានបើកប្រាក់បៀវត្សប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-បានតាមដានគោលការណ៍ និងព័ត៌មានទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

-បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៨២១លើក

-បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៩៥សំណើ

-បានថតចម្លងឯកសារចំនួន៥,៣២៥ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៣៨ក្បាល អស់ក្រដាសសរុបចំនួន៣៨,៧៩៨សន្លឹក

-បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន២១៥លើក ស្មើនឹង២៧១នាក់។ បានប្តូរប្រេងម៉ាស៊ីនរថយន្តចំនួន០៨គ្រឿង ប្តូរអាគុយរថយន្តចំនួន០១គ្រឿង និងជួសជុលរថយន្តចំនួន០៤គ្រឿង

-បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣០លើក

-បានទទួលលិខិតចូលចំនួន៣៦៩ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤១៨ច្បាប់

-បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៩ច្បាប់ ស្មើនឹង១៩០នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៦ច្បាប់

ស្មើនឹង០៦នាក់

-បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន ១១នាក់

-បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-បានបែងចែកប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភាឆ្នាំ២០២៣ ចំនួន៤២៨សន្លឹក

-បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៨លើក

-បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

-បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

-បានទទួលលិខិតសុំអនុញ្ញាតច្បាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងកត់ត្រាចូលក្នុងសៀវភៅការងារចំនួន៨០ច្បាប់

-បានធ្វើសេចក្តីសម្រេច និងលិខិតបង្គាប់ការចំនួន១៣ច្បាប់

-បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន៥៩ប័ណ្ណ

-បានធ្វើសេចក្តីជូនដំណឹងផ្សព្វផ្សាយអាហារូបករណ៍នានា ក្នុងប្រទេសចំនួន០៨កន្លែង និងអាហារូបករណ៍ក្រៅប្រទេសចំនួន០៤កន្លែង សម្រាប់ឆ្នាំសិក្សា២០២៣-២០២៤

-បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន១១០នាក់ និងក្រៅប្រទេសចំនួន០៤វគ្គ មានសិក្ខាកាមចូលរួមចំនួន០៤នាក់

-បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី វគ្គវិធីសាស្ត្រសរសេរគម្រោង និងវគ្គកម្មវិធីពង្រឹងសមត្ថភាព ដើម្បីអភិវឌ្ឍសមត្ថភាពសារពើពន្ធ

-បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូ សិស្ស និងនិស្សិត នៅព្រឹទ្ធសភាចំនួន០៣លើក

-បានរៀបចំជួសជុលបន្ទប់ក្រោមអគារក្រហមនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបំពាក់សម្ភារ និងជួសជុលកែលម្អៈ ហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក, ត្រួតពិនិត្យជណ្តើរយន្ត សត្វកណ្តៀរ, រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, ប្រមូលសម្ភារខូច, បិទលេខកូដសម្ភារសារពើភ័ណ្ឌ, ប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គ-

លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន២១៥គ្រឿង/លើក

–បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន៤១លើក

–បានធ្វើរបាយការណ៍ចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៩ និងលើកទី១០ នីតិកាលទី៤

–បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា

–បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៨លើក។

**៩.២-ការងារសេវាច្បាប់៖**

–បានទទួលសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់ ពីរដ្ឋសភា

–បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗចំនួន៤៦៨ច្បាប់

–បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៨ច្បាប់

–បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និងនីតិកាលនីមួយៗ។

**៩.៣-ការងារស្រាវជ្រាវ៖**

–បានផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០២ច្បាប់

–បានសិក្សាស្រាវជ្រាវ និងធ្វើសំយោគឯកសារព័ត៌មាន និងសង្ខេបខ្លឹមសារពាក់ព័ន្ធវិស័យនានាចំនួន៩២ច្បាប់

–បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥)

–បានផលិតទិន្នន័យតាមវិស័យរបស់គណៈកម្មការជំនាញទាំង១០ចំនួន៨៧ច្បាប់

–បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៩៨អត្ថបទ

–បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ចំនួន០៤ច្បាប់។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

–បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលកុំព្យូទ័រ និងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន១៦៩គ្រឿង/លើក។ បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៨៥ប្រធានបទ

–បានរៀបចំកម្មវិធីទូរស័ព្ទ (Mobile Application) សម្រាប់គាំទ្រទៅលើការផ្សព្វផ្សាយពីដំណើរការ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភា ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជន

–បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន២០៨ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ុតក្របសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន១០០ក្បាល

–បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្ដីពី សកម្មភាព និងលទ្ធផលការងារព្រឹទ្ធសភាចំនួន១៥លើក

–បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន២៨៦លើក

–បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Channel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន២,៨១២ប្រធានបទ

–បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៤៧លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២១លើក

–បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពនៅមុខអគារក្រហម និងខ្លោងទ្វារធំព្រឹទ្ធសភាចំនួន១៥លើក

–បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្ដាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿនល្អ និងរលូន។

**៤.៥-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

–បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៤លើក

–បានរៀបចំ និងបញ្ជូនសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងរំលែកទុក្ខ

របស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជូនឥស្សរជនជាន់ខ្ពស់នៃបណ្តាប្រទេសជាមិត្តចំនួន០៧លើក

-បានកសាងជំនួយស្មារតី និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន១៨ច្បាប់

-បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៧ច្បាប់

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ចំនួន ០១ច្បាប់

-បានតុបតែងលម្អ ចងបដា ពាក្យស្លោកក្នុងពិធីបុណ្យមាឃបូជា។

**៨.៦-ការងារអគ្គាធិការដ្ឋាន៖**

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកុម្ភៈ ឆ្នាំ២០២៣ ចំនួន១៩លើក

-បានប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

-បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

-បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន៣៨លើក ប្រចាំសប្តាហ៍ចំនួន ០៤លើក និងប្រចាំខែកុម្ភៈ ឆ្នាំ២០២៣

-បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែកុម្ភៈ ឆ្នាំ២០២៣។

**II-ទិសដៅការងារខែមីនា ឆ្នាំ២០២៣**

-ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ ជំងឺកូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ

-បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក

-ធានាប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-

ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

–ត្រៀមទទួលរថយន្តចំនួន០៥គ្រឿង ដែលជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន។

**១- មុខងារនីតិកម្ម**

–ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងបើកសម័យប្រជុំលើកទី៩ និងទី១០ នីតិកាលទី៤ ដើម្បី៖

១-ស្តាប់របាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ នីតិកាលទី៤

២-សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

**២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

–ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា ក្នុងរយៈពេលវិស្សមកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣។

**៣- មុខងារតំណាង**

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជួបសំណេះសំណាលជាមួយគណៈប្រតិភូជាតិនារីចំនួន ២០០នាក់ (ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣)

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំអញ្ជើញជាអធិបតីក្នុងពិធីកាត់ឬសសីមាព្រះវិហារ នៅឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង (ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣)

–ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ចុះធ្វើវេទិកាជាមួយក្រុមប្រឹក្សាសង្កាត់ ស្តីពី ការអភិវឌ្ឍមូលដ្ឋាន និងបម្រើប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពធានាបានសុខសន្តិភាព ចំនួន៩ខណ្ឌ (ខណ្ឌដូនពេញ ខណ្ឌ៧មករា ខណ្ឌទួលគោក ខណ្ឌឫស្សីកែវ ខណ្ឌជ្រោយចង្វារ ខណ្ឌមានជ័យ ខណ្ឌបឹងកេងកង ខណ្ឌចំការមន និងខណ្ឌច្បារអំពៅ) (ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣)

–ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម និងក្រុមប្រឹក្សាឃុំ នៅស្រុកតំបែរ ខេត្តត្បូងឃ្មុំ (ខែមីនា ឆ្នាំ២០២៣)

–ត្រៀមរៀបចំជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ជួបពិភាក្សាការងារជាមួយក្រុម

ប្រឹក្សាឃុំនៅសាលប្រជុំសាលាស្រុកភ្នំព្រឹក និងជាមួយក្រុមប្រឹក្សានៅសាលាស្រុកសំពៅលូន ខេត្តបាត់ដំបង (ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៣)

–ត្រៀមរៀបចំពិធីអបអរទិវាអន្តរជាតិនារី ០៨មីនា លើកទី១១២ ក្រោមប្រធានបទ "ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" (ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣)។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

–ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអគ្គទូតនានានៃប្រទេសជាមិត្ត

–ត្រៀមទទួលដំណើរទស្សនកិច្ចៈ

+គណៈប្រតិភូអគ្គលេខាធិការសភាថៃ

+គណៈកម្មការគោលនយោបាយសង្គមកិច្ចរបស់ព្រឹទ្ធសភា នៃសាធារណរដ្ឋឆែក

–ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញៈ

+ចូលរួមប្រជុំមហាសន្និបាតសហភាពអន្តរសភា(IPU-146)នៅព្រះរាជាណាចក្របារ៉ែន (ថ្ងៃទី១១-១៥ ខែមីនា ឆ្នាំ២០២៣)

+ចូលរួមកម្មសិក្សា នៅព្រឹទ្ធសភាកាណាដា (ថ្ងៃទី២៤-២៨ ខែមេសា ឆ្នាំ២០២៣)

–ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ

–ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

–តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCAsia) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

–បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

–ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត និងដៃគូផ្សេងៗទៀត។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

–ត្រៀមរៀបចំគម្រោងថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២៤

–ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែមីនាឆ្នាំ២០២៣ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឱ្យបានទាន់ពេលវេលា

–បន្តវិចារណកម្មថវិកាៈ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុតៈ

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឈមនឹងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងប្លាស្ទិក)

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ច របស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំការងារកែសម្រួលឋានន្តរសក្តិ និងការតែងតាំងក្នុងមុខតំណែង

-ត្រៀមប្រឡងប្តូរក្របខ័ណ្ឌ សម្រាប់មន្ត្រីរាជការបានរៀនបញ្ចប់សញ្ញាបត្រថ្មីដែលខ្ពស់ជាងក្របខ័ណ្ឌបច្ចុប្បន្ន

-ត្រៀមប្រជុំគណៈកម្មការ ដើម្បីពិនិត្យវាយតម្លៃសម្រាប់ដំឡើងថ្នាក់បៀវត្សប្រចាំឆ្នាំ២០២៣

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីៗ ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែងចំនួន០៣គឺ៖

១-គោលការណ៍ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម

២-គោលការណ៍ស្តីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ

៣-គោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្ស

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ធ្វើសម្រង់តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការប្រចាំឆ្នាំ២០២៣

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី៖ វគ្គសេដ្ឋកិច្ច ឌីជីថល, វគ្គវិភាគសារពើភ័ណ្ឌ, វគ្គAdvanced English Language and Communication Skill នៅមជ្ឈមណ្ឌលICON និងវគ្គSpecialized Training Programme on Select WTO Issues Agriculture Services TRIPS and RTAS នៅប្រទេសឥណ្ឌា

-បន្តតាមដានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន ស្ថានទូតវៀតណាម ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា គម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ

-បន្តសិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី ប្លង់សាងសង់

របស់ថ្មីខាងមុខព្រឹទ្ធសភា និងជួសជុលសាលបដិសណ្ឋារកិច្ច

–បន្តរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥ របស់ព្រឹទ្ធសភា និងការត្រៀមជាបណ្ដើរៗ ការរៀបចំជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំងការបំពាក់សម្ភារៈ

–បន្តការងារជួសជុលថែទាំអគារ ជួសជុលអគារក្រហម និងជួសជុលផ្លាស់ប្ដូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

–បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

–លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

–ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

–បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភានៃប្រទេសជាមិត្ត

–បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

–ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**III-សេចក្តីសន្និដ្ឋាន**

ក្នុងខែកុម្ភៈនេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា មានភាពមមាញឹក និងសកម្មលើគ្រប់មុខងារ ហើយទទួលបានលទ្ធផលល្អប្រសើរ។ លទ្ធផលទាំងនេះក៏ផ្ដើមចេញពីការខិតខំប្រឹងប្រែងប្រកបដោយវិជ្ជាជីវៈក្នុងការផ្ដល់សេវាគាំទ្រពីគ្រប់អង្គភាពរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាផងដែរ។

សកម្មភាពការងារលេចធ្លោ ហើយទទួលបានលទ្ធផលជាទីមោទនៈសម្រាប់ស្ថាប័ន គឺការផ្ដល់សេវាសម្រាប់បម្រើឱ្យការងារបដិសណ្ឋារកិច្ចគណៈប្រតិភូប្រធានាធិបតីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់តំណាងឱ្យជាតិទាំងមូល។

ការរៀបចំទាំងមូលនៃដំណើរទស្សនកិច្ចនេះ បានជោគជ័យ និងបានឆ្លុះបញ្ចាំងអំពីភាពជោគជ័យនៃកិច្ចសហប្រតិបត្តិការអន្តរស្ថាប័នល្អប្រពៃជាមួយស្ថាប័ន ក្រសួង អាជ្ញាធររាជធានី និងខេត្តសៀមរាប

ព្រមទាំងភាពស្អិតរមួត ស៊ីសង្វាក់គ្នានៃកិច្ចសហប្រតិបត្តិការផ្ទៃក្នុង។

ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ជំនាន់ទី៣ គឺជាឧបករណ៍ថ្មីនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលទាំងអស់គ្នាត្រូវរៀនសូត្រ និងប្រតិបត្តិឱ្យបានរលូន និងត្រឹមត្រូវតាមច្បាប់ជាធរមាន។

មន្ត្រីរាជការទាំងអស់ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បានដាក់ចេញ ជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន។៚

ថ្ងៃអង្គារ ១[illegible] ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣

**អគ្គលេខាធិការ**

**អ៊ុំ សារិទ្ធ**